អង្គរបស់អ្នកសូត្រ ៣ អ្នកស្តាប់ ៣

១-អត្ថញ្ច ព្យញ្ជនញ្ច បរិសោធេត្វា សុដ្ឋុ ឧគ្គហិតា ជម្រះអត្ថ និងព្យញ្ជនៈ ឱ្យត្រឹមត្រូវហើយ រៀនយកដោយល្អ (គឺរៀនឱ្យត្រូវតាមសំឡេងអក្សរ)

២-បទព្យញ្ជនានិ អហាបេត្វា បរិបុណ្ណំ ឧគ្គហិតា រៀនយកឱ្យគ្រប់បរិបូណ៌ មិនឱ្យបទនិងព្យញ្ជនៈបាត់បង់ (គឺសូត្រតាមលំដាប់ពីដើម ដល់ចប់)

៣-លាភហេតុ ឧគ្គហិត្វា ភណន្តស្សាបិ អត្ថំ ន សាធេតិ មិនរៀនយកព្រោះលាភជាហេតុ ហើយស្វាយធ្យាយ (គឺត្រូវសូត្រដោយមេត្តា)

១-កម្មាវរណេន មិនមានការហាម ដោយអនន្តរិយកម្ម ៥

២-កិលេសាវរណេន មិនមានការហាម ដោយនិយតមិច្ឆាទិដ្ឋិ

៣-សទ្ធហនតាយ មានការជឿ នូវអានុភាពនៃព្រះបរិត្ត

អាដានាដិយសូត្រ អដ្ឋកថា + មិលិន្ទបញ្ហា អភេជ្ជវគ្គ បញ្ហាទី៤

រោគមាន ៤ គឺ រោគកើតពីកម្ម កើតពីចិត្ត កើតពីអាហារ កើតពីអាកាសធាតុ
វិធីមាន ៣ គឺ ការពារ បញ្ចៀស រក្សា
វត្ថុមាន ២ គឺ ទឹកបរិត្ត អំបោះបរិត្ត

រៀបចំដោយ ព្រះមហាថេរៈខន្តី

មនុស្សសម្បុរខ្មៅ ឬ ស មិនសំខាន់ឡើយ សំខាន់គឺគាត់អាចជួយយើងបាន

រតនបរិត្ត

១. យាˋនីធ ភូតានិ សមាគតានិ,
ភុម្មានិ វា យានិ វ អន្តលិក្ខេ;
សព្វេវ ភូតា សុមនា ភវន្តុ,
អថោបិ សក្កច្ច សុណន្តុ ភាសិតំ។

២. តស្មា ហិ ភូតា និសាមេថ សព្វេ,
មេត្តំ ករោថ មានុសិយា បជាយ;
ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ,
តស្មា ហិ នេ រក្ខថ អប្បមត្តា។

៣. យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា,
សគ្គេសុ វា យំ រតនំ បណីតំ;
ន នោ សមំ អត្ថិ តថាគតេន,
ឥទម្បិ **ពុទ្ធេ** រតនំ បណីតំ;
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៤. ខយំ វិរាគំ អមតំ បណីតំ,
យទជ្ឈគា សក្យមុនី សមាហិតោ;
ន តេន ធម្មេន សមត្ថិ កិញ្ចិ,
ឥទម្បិ **ធម្មេ** រតនំ បណីតំ;
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៥. យំ ពុទ្ធˋសេដ្ឋោ បរិវណ្ណយី សុចិំ,
សមាធិˋមានន្តរិកញ្ញˋមាហុ;
សមាធិនា តេន សមោ ន វិជ្ជតិ,
ឥទម្បិ **ធម្មេ** រតនំ បណីតំ;
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៦. យេ បុគ្គលា អដ្ឋ សតំ បសត្ថា,
ចត្តារិ ឯតានិ យុគានិ ហោន្តិ;
តេ ទក្ខិណេយ្យា សុគតស្ស សាវកា,
ឯតេសុ ទិន្នានិ មហប្ផលានិ;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៧. យេ សុប្បយុត្តា មនសា ទឡ្ហេន,
និក្កាមិនោ គោតមសាសនម្ហិ;
តេ បត្តិបត្តា អមតំ វិគយ្ហ,
លទ្ធា មុធា និព្វុតឹ ភុញ្ជមានា;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៨. យថិន្ទខីលោ បថវិស្សិតោ សិយា,
ចតុព្ភិ វាតេហិ អសម្បកម្បិយោ;
តថូបមំ សប្បុរិសំ វទាមិ,
យោ អរិយសច្ចានិ អវេច្ច បស្សតិ;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

៩. យេ អរិយសច្ចានិ វិភាវយន្តិ,
គម្ភីរបញ្ញេន សុទេសិតានិ;
កិញ្ចាបិ តេ ហោន្តិ ភុសំ បមត្តា,
ន តេ ភវំ អដ្ឋមមាទិយន្តិ;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

១០. សហាវស្ស ទស្សន់សម្បទាយ,
តយស្សុ ធម្មា ជហិតា ភវន្តិ;
សក្កាយ់ ទិដ្ឋិ វិចិកិច្ឆិតញ្ច,
សីលព្វតំ វាបិ យទត្ថិ កិញ្ចិ។

១១. ចតូ់ហបាយេហិ ច វិប្បមុត្តោ,
ឆច្ចាភិឋានានិ អភព្វ កាតុំ;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

១២. កិញ្ចាបិ សោ កម្ម ករោតិ បាបកំ,
កាយេន វាចា ឧទ ចេតសា វា;
អភព្វ សោ តស្ស បដិច្ឆទាយ,
អភព្វតា ទិដ្ឋបទស្ស វុត្តា;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

១៣. វនប្បគុម្ពេ យថ ផុស្សិតគ្គេ,
គិម្ហាន់មាសេ បឋមស្មឹ គិម្ហេ;
តថូបមំ ធម្មវរំ អទេសយិ,
និព្វាន់គាមឹ បរមំ ហិតាយ;
ឥទម្បិ **ពុទ្ធេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

១៤. វរោ វរញ្ញូ វរទោ វរាហរោ,
អនុត្តរោ ធម្មវរំ អទេសយិ;
ឥទម្បិ **ពុទ្ធេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

១៥. ខីណំ បុរាណំ នវ នត្ថិ សម្ភវំ,
វិរត្ត់ចិត្តា់យតិកេ ភវស្មឹ;
តេ ខីណពីជា អវិរូឡ្ហិច្ឆន្ទា,
និព្វន្តិ ធីរា យថាយំ បទីបោ;
ឥទម្បិ **សង្ឃេ** រតនំ បណីតំ,
ឯតេន សច្ចេន សុវត្ថិ ហោតុ។

****

១៦. យា់នីធ ភូតានិ សមាគតានិ,
ភុម្មានិ វា យានិ វ អន្តលិក្ខេ;
តថាគតំ ទេវមនុស្សបូជិតំ,
ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ។

១៧. យា់នីធ ភូតានិ សមាគតានិ,
ភុម្មានិ វា យានិ វ អន្តលិក្ខេ;
តថាគតំ ទេវមនុស្សបូជិតំ,
ធម្មំ នមស្សាម សុវត្ថិ ហោតុ។

១៨. យា់នីធ ភូតានិ សមាគតានិ,
ភុម្មានិ វា យានិ វ អន្តលិក្ខេ;
តថាគតំ ទេវមនុស្សបូជិតំ,
សង្ឃំ នមស្សាម សុវត្ថិ ហោតុ។

ចម្លងពីច្បាប់ឆដ្ឋសង្គាយនា
(បិដកខ្មែរលេខ៥២ ទំព័រ៦, លេខ៥៤ ទំព័រ៧៣,
អដ្ឋកថាធម្មបទ បកិណ្ណកវគ្គ រឿងអត្តនោបុព្វកម្ម)
ដោយព្រះមហាញាណវុធៈ ទុយ លីហួរ (29-03-2020)

មេត្តបរិត្ត

(ប្រើសូធ្យផ្សាយមេត្តាដល់អមនុស្សកុំឱ្យបៀតបៀនយើង។

១. ករណីយមត្ថកុសលេន,
យន្តំ សន្តំ បទំ អភិសមេច្ច;
សក្កោ ឧជូ ច សុហុជូ ច,
សុវចោ ចស្ស មុទុ អនតិមានី ។

២. សន្តុស្សកោ ច សុភរោ ច,
អប្បកិច្ចោ ច សល្លហុកវុត្តិ;
សន្តិន្ទ្រិយោ ច និបកោ ច,
អប្បគព្ភោ កុលេសុ អននុគិទ្ធោ ។

៣. ន ច ខុទ្ទំ សមាចរេ កិញ្ចិ,
យេន វិញ្ញូ បរេ ឧបវទេយ្យុំ;
សុខិនោ វា ខេមិនោ ហោន្តុ,
សព្វេ សត្តា ភវន្តុ សុខិតត្តា ។

៤. យេ កេចិ បាណភូតត្ថិ,
តសា វា ថាវរា វា អនវសេសា;
ទីឃា វា យេ មហន្តា វា,
មជ្ឈិមា រស្សកា អណុកថូលា ។

៥. ទិដ្ឋា វា យេ ច អទិដ្ឋា,
យេ ច ទូរេ វសន្តិ អវិទូរេ;
ភូតា វា សម្ភវេសី វា,
សព្វេ សត្តា ភវន្តុ សុខិតត្តា ។

៦. ន បរោ បរំ និកុព្វេថ,
នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ;
ព្យារោសនា បដិឃសញ្ញា,
នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ ។

៧. មាតា យថា និយំ បុត្តំ,
អាយុសា ឯកបុត្តមនុរក្ខេ;
ឯវម្បិ សព្វភូតេសុ,
មានសម្ភាវយេ អបរិមាណំ ។

៨. មេត្តញ្ច សព្វលោកស្មឹ,
មានសម្ភាវយេ អបរិមាណំ;
ឧទ្ធំ អធោ ច តិរិយញ្ច,
អសម្ពាធំ អវេរំ អសបត្តំ ។

៩. តិដ្ឋញ្ចរំ និសិន្នោ វា,
សយានោ វា យាវតស្សវិគតមិទ្ធោ;
ឯតំ សតឹ អធិដ្ឋេយ្យ,
ព្រហ្មមេតំ វិហារំ ឥធមាហុ ។

១០. ទិដ្ឋញ្ច អនុបគម្ម,
សីលវា ទស្សនេន សម្បន្នោ;
កាមេសុ វិនេយ្យ គេធំ,
ន ហិ ជាតុគព្ភសេយ្យំ បុន រេតិ ។

ដកស្រង់ពី បិដកលេខ៥២ ទំព័រ១៨, លេខ៥៤ ទំព័រ៥០)
ធម្មបទអដ្ឋកថា ចិត្តវគ្គ រឿងទី ៦ អារទ្ធវិបស្សកភិក្ខុ
ដោយព្រះមហាញាណវុធៈ ទុយ លីហួរ (15-04-2020)

រតនបរិត្តបាលី-ប្រែ

១. *យានីធ ភូតានិ សមាគតានិ, ភុម្មានិ វា យានិ វ អន្តលិក្ខេ;* =ពួកភូតឯណា ជាទេវតាឋិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

សព្វេវ ភូតា សុមនា ភវន្តុ, =សូមពួកភូតទាំងអស់នោះមានចិត្តល្អ

អថោបិ សក្កច្ច សុណន្តុ ភាសិតំ =ម្យ៉ាងទៀត ចូរស្តាប់នូវភាសិតដោយគោរព។

២. *តស្មា ហិ ភូតា និសាមេថ សព្វេ, មេត្តំ ករោថ មានុសិយា បជាយ;* =ព្រោះហេតុនោះ អ្នកទាំង-ឡាយជាភូតទាំងអស់ ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្ត ចំពោះពពួកសត្វជាមនុស្សជាតិ

ទិវា ច រត្តោ ច ហរន្តិ យេ ពលិំ =មនុស្សទាំងឡាយឯណា តែងនាំមកនូវពលិកម្មក្នុងពេលថ្ងៃ និងពេលយប់

តស្មា ហិ នេ រក្ខថ អប្បមត្តា =ព្រោះហេតុនោះ សូមអ្នកទាំងឡាយកុំមើលបំណាំឡើយ សូមរក្សា នូវមនុស្សទាំងឡាយនោះ។

៣. *យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា, សគ្គេសុ វា យំ រតនំ បណីតំ;* =ទ្រព្យឯណាមួយ ក្នុងលោកនេះ និងក្នុងលោកឯទៀតក្តី រតនវត្ថុដ៏ឧត្តមឯណា ក្នុងឋានសួគ៌ក្តី

ន នោ សមំ អត្ថិ តថាគតេន =ទ្រព្យ និងរតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគត មិនមានឡើយ

ឥទម្បិ **ពុទ្ធេ** *រតនំ បណីតំ* =កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

៤. *ខយំ វិរាគំ អមតំ បណីតំ, យទជ្ឈគា សក្យមុនី សមាហិតោ;* =ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយ នូវព្រះធម៌ឯណា ជាទីក្ស័យនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ដ៏ឧត្តម

ន តេន ធម្មេន សមត្ថិ កិញ្ចិ =របស់អ្វីមួយ ស្មើដោយព្រះធម៌នោះ មិនមានឡើយ

ឥទម្បិ **ធម្មេ** *រតនំ បណីតំ* =កែវ គឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

៥. *យំ ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចិំ* =ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិឯណា ថាជាធម៌ដ៏ស្អាត

សមាធិមានន្តរិកញ្ញមាហុ បណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិឯណា ថាជាធម៌ឱ្យផលដោយលំដាប់

សមាធិនា តេន សមោ ន វិជ្ជតិ =សមាធិឯទៀត ស្មើដោយសមាធិនោះមិនមានឡើយ

ឥទម្បិ **ធម្មេ** *រតនំ បណីតំ* =កែវ គឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។

៦. យេ បុគ្គលា អដ្ឋ សតំ បសត្ថា, ចត្តារិ ឯតានិ យុគានិ ហោន្តិ; =បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ

តេ ទក្ខិណេយ្យា សុគតស្ស សាវកា =បុគ្គលទាំងឡាយនោះ ជាសាវ័ក របស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន

ឯតេសុ ទិន្នានិ មហប្ផលានិ =ទានទាំងឡាយ ដែលបុគ្គលឱ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន

ឥទម្បិ **សង្ឃេ** រតនំ បណីតំ, =កែវគឺ ព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។

៧. យេ សុប្បយុត្តា មនសា ទឡ្ហេន, និក្កាមិនោ គោតមសាសនម្ហិ; =អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនានៃព្រះសម្ពុទ្ធ ទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានកាម គឺសេចក្តីប្រាថ្នាឡើយ

តេ បត្តិបត្តា អមតំ វិគយ្ហ,

លទ្ធា មុធា និព្វុតឹ ភុញ្ជមានា; =អរិយបុគ្គល ទាំងឡាយនោះ ដល់ហើយនូវព្រះអរហត្តផល ហើយចូលទៅកាន់ព្រះនិព្វាន បាននូវកិរិយារលត់កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយនូវផល

ឥទម្បិ **សង្ឃេ** រតនំ បណីតំ =កែវគឺ ព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

៨. យថិន្ទខីលោ បឋវិស្សិតោ សិយា, ចតុព្ភិ វាតេហិ អសម្បកម្បិយោ; =សសរខឿនដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រ ដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ

តថូបមំ សប្បុរិសំ វទាមិ, យោ អរិយសច្ចានិ អវេច្ច បស្សតិ; =អ្នកណាពិចារណាឃើញនូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ) ប្រៀបដូចជាសសរខឿនដូច្នោះឯង

ឥទម្បិ **សង្ឃេ** រតនំ បណីតំ =កែវគឺ ព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

៩. យេ អរិយសច្ចានិ វិភាវយន្តិ, គម្ភីរបញ្ញេន សុទេសិតានិ; =អរិយបុគ្គលទាំងឡាយឯណា ធ្វើឱ្យជាក់ច្បាស់ នូវអរិយសច្ចទាំងឡាយ ដែលព្រះតថាគតព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សម្តែងល្អហើយ

កិញ្ចាបិ តេ ហោន្តិ ភុសំ បមត្តា =អរិយបុគ្គលទាំងឡាយនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ

ន តេ ភវំ អដ្ឋមមាទិយន្តិ =អរិយបុគ្គលទាំងឡាយនោះ គង់មិនកាន់យកនូវភពជាគម្រប់ ៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ

ឥទម្បិ **សង្ឃេ** រតនំ បណីតំ =កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១០. សហាវស្ស ទស្សនៈសម្បទាយ, តយស្សុ ធម្មា ជហិតា ភវន្តិ;

សក្កាយៈទិដ្ឋិ វិចិកិច្ឆិតញ្ច, សីលព្វតំ វាបិ យទត្ថិ កិញ្ចិ = (សំយោជនកិលេស ៣ យ៉ាងគឺ) សក្កាយទិដ្ឋិវិចិកិច្ឆា និងសីលព្វតបរាមាសឯណាមួយ តែងមាន ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះបានលះបង់ហើយ ជាមួយនឹងទស្សនសម្ប៉ទ គឺសោតាបត្តិមគ្គ

១១. ចតូហបាយេហិ ច វិប្បមុត្តោ ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះចាកអបាយទាំងឡាយ ៤ ហើយ

ឆច្ចាភិឋានានិ អភព្វ កាតុំ =មិនអាចធ្វើនូវឋានដ៏អាក្រក់ទាំងឡាយ ៦ គឺអនន្តរិយកម្ម ៥ និងកិរិយាងាកចិត្តទៅកាន់សាសនាដទៃឡើយ

ឥទម្បិ **សង្ឃេ** រតនំ បណីតំ =កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១២. កិញ្ចាបិ សោ កម្ម ករោតិ បាបកំ, កាយេន វាចា ឧទ ចេតសា វា; =ប្រសិនណា បើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មខ្លះ ដោយកាយ វាចា ឬក៏ដោយចិត្ត (ព្រោះសេចក្ដីភ្លាំងភ្លាត់)

អភព្វ សោ តស្ស បដិច្ឆទាយ =សោតាបន្នបុគ្គលនោះ មិនអាចបិទបាំង នូវបាបកម្មនោះឡើយ

អភព្វតា ទិដ្ឋបទស្ស វុត្តា =ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វាន ឃើញហើយ ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម ព្រះពុទ្ធទាំងឡាយបានត្រាស់សម្ដែងហើយ

ឥទម្បិ **សង្ឃេ** រតនំ បណីតំ =កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១៣. វនប្បគុម្ពេ យថ ផុស្សិតគ្គេ, គិម្ហានៈមាសេ បឋមស្មិំ គិម្ហេ; =គុម្ពឈើ ក្នុងព្រៃ មានត្រួយលូតលាស់ក្នុងខាងដើមគិម្ហរដូវ គឺខែក្ដៅយ៉ាងណាមិញ

តថូបមំ ធម្មវរំ អទេសយិ, និព្វានៈគាមិំ បរមំ ហិតាយ; =ព្រះសម្ពុទ្ធបានត្រាស់សម្ដែងហើយ នូវធម៌ដ៏ប្រសើរ ជាធម៌អាចញ៉ាំងសត្វទាំងឡាយ ឱ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ប្រៀបដូចជាគុម្ពឈើក្នុងព្រៃដូច្នោះឯង

ឥទម្បិ **ពុទ្ធេ** រតនំ បណីតំ =កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១៤. វរោ វរញ្ញូ វរទោ វរាហរោ =ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ

អនុត្តរោ ធម្មវរំ អទេសយិ ព្រះអង្គប្រសើរឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្ដែងហើយនូវធម៌ដ៏ប្រសើរ

ឥទម្បិ **ពុទ្ធេ** រតនំ បណីតំ =កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១៥. *ខីណំ បុរាណំ នវ នត្ថិ សម្ភវំ* =កម្មចាស់ (របស់អរិយបុគ្គលឯណា) អស់ហើយ កម្មថ្មីរមែងមិនកើតប្រាកដ

វិរត្តចិត្តា យតិកេ ភវស្មិំ =អរិយបុគ្គលទាំងឡាយឯណា មានចិត្តនឿយណាយហើយ ក្នុងភពតទៅ

តេ ខីណពីជា អវិរូឡ្ហិឆន្ទា =អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ង ក្នុងចិត្តមិនដុះចម្រើនឡើយ

និព្វន្តិ ធីរា យថាយំ បទីបោ =ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីបដែលរលត់ទៅនេះ

ឥទម្បិ **សង្ឃេ** *រតនំ បណីតំ* =កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ =ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

១៦. *យានីធ ភូតានិ សមាគតានិ, ភុម្មានិ វា យានិ វ អន្តលិក្ខេ;* =ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

តថាគតំ ទេវមនុស្សបូជិតំ, **ពុទ្ធំ** *នមស្សាម សុវត្ថិ ហោតុ* =យើងទាំងឡាយ សូមនមស្ការ នូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា សូមសិរីសួស្តីកើតមាន

១៧. *យានីធ ភូតានិ សមាគតានិ, ភុម្មានិ វា យានិ វ អន្តលិក្ខេ;* =ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

តថាគតំ ទេវមនុស្សបូជិតំ, **ធម្មំ** *នមស្សាម សុវត្ថិ ហោតុ* =យើងទាំងឡាយ សូមនមស្ការ នូវព្រះធម៌ មានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមសិរីសួស្តីកើតមាន។

១៨. *យានីធ ភូតានិ សមាគតានិ, ភុម្មានិ វា យានិ វ អន្តលិក្ខេ;* =ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

តថាគតំ ទេវមនុស្សបូជិតំ, **សង្ឃំ** *នមស្សាម សុវត្ថិ ហោតុ* =យើងទាំងឡាយ សូមនមស្ការ នូវព្រះសង្ឃ មានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមសិរីសួស្តីកើតមាន។

បាលីចម្លងពីច្បាប់ឆដ្ឋសង្គាយនា

(បិដកខ្មែរលេខ៥២ ទំព័រ៦, លេខ៥៤ ទំព័រ៧៣,

អដ្ឋកថាធម្មបទ បកិណ្ណកវគ្គ រឿងអត្តនោបុព្វកម្ម)

ដោយព្រះមហាញាណវុធៈ ទុយ លីហូរ (29-03-2020)

មេត្តបរិត្ត

(ប្រើសូធ្យផ្សាយមេត្តាដល់អមនុស្សខ្មោចកុំឱ្យបៀតបៀនយើង។ បិ-៥២/១៨, ៥៤/៥០)
ធម្មបទអដ្ឋកថា ចិត្តវគ្គ រឿងទី ៦ អារទ្ធវិបស្សកភិក្ខុ

១. *ករណីយមត្ថកុសលេន,* *យន្តំ សន្តំ បទំ អភិសមេច្ច* កិច្ចឯណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវកោដ្ឋាសនៃធម៌ដ៏ស្ងប់រំងាប់ គឺព្រះនិព្វាន (បានធ្វើហើយ), កិច្ចនោះ គឺកុលបុត្រកត្រកឆ្លាសក្នុងប្រយោជន៍គួរធ្វើ

សក្កោ ឧជូ ច សុហុជូ ច (កុលបុត្រនោះ) [1]ជាអ្នកអាចហ៊ានផង [2]ត្រង់ដោយកាយ និងវាចាផង [3]ត្រង់ល្អដោយចិត្តផង

សុវចោ ចស្ស មុទុ អនតិមានី [4]ជាអ្នកប្រដៅងាយផង [5]សុភាពទន់ភ្លន់ផង [6]មិនមានមានះដ៏ក្រៃលែងផង

២. *សន្តុស្សកោ ច សុភរោ ច* [7]ជាអ្នកសន្តោសផង [8]គេចិញ្ចឹមងាយផង

អប្បកិច្ចោ ច សល្លហុកវុត្តិ [9]ជាអ្នកមានកិច្ចធុរៈតិចផង [10]ប្រព្រឹត្តស្រាល (ក្នុងកាយ និងចិត្ត) ផង

សន្តិន្ទ្រិយោ ច និបកោ ច [11]ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង [12]មានប្រាជ្ញាចាស់ផង

អប្បគព្ភោ កុលេសុ អននុគិទ្ធោ [13]ជាអ្នកមិនឆ្គងផង [14]មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង

៣. *ន ច ខុទ្ទំ សមាចរេ កិញ្ចិ,* *យេន វិញ្ញូ បរេ ឧបវទេយ្យុំ* វិញ្ញូជនទាំងឡាយ គួរតិះដៀលនូវជនទាំងឡាយដទៃដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកសត្វថា)

សុខិនោ វា ខេមិនោ ហោន្តុ, *សព្វេ សត្តា ភវន្តុ សុខិតត្តា* សត្វទាំងឡាយទាំងពួង សូមឱ្យមានសេចក្តីសុខ ឱ្យមានសេចក្តីក្សេម ឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ

៤. *យេ កេចិ បាណភូតត្ថិ,* *តសា វា ថាវរា វា អនវសេសា* សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ [១]ទោះសត្វដែលជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី, [២]ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី

ទីឃា វា យេ មហន្តា វា សត្វទាំងឡាយឯណា [៣]មានកាយវែងក្តី [៤]ធំក្តី

មជ្ឈិមា រស្សកា អណុកថូលា [៥]មានកាយយ៉ាងកណ្តាលក្តី [៦]ខ្លីក្តី [៧]មានកាយដ៏ស្តួម [៨]ឬធាត់ក្តី

៥. *ទិដ្ឋា វា យេ ច អទិដ្ឋា* សត្វទាំងឡាយឯណា [៩]ដែលយើងឃើញហើយក្តី [១០]មិនឃើញក្តី

យេ ច ទូរេ វសន្តិ អវិទូរេ សត្វទាំងឡាយឯណា [១១]នៅក្នុងទីឆ្ងាយក្តី [១២]ក្នុងទីជិតក្តី

ភូតា វា សម្ភវេសី វា [១៣]ដែលកើតរួចមកហើយក្តី [១៤]ដែលកំពុងស្វែងរកទីកើតក្តី

សព្វេ សត្តា ភវន្តុ សុខិតត្តា សត្វទាំងឡាយទាំងពួង សូមឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ

៦. *ន បរោ បរំ និកុព្វេថ* [1]សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ

នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ [2]មិនគួរមើលងាយគេតិចតួចក្នុងទីឯណាមួយឡើយ

ព្យាបេសនា បដិឃសញ្ញា, នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ [3]មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ

៧. មាតា យថា និយំ បុត្តំ, អាយុសា ឯកបុត្តមនុរក្ខេ មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្របានយ៉ាងណាមិញ

ឯវម្បិ សព្វភូតេសុ, មានសម្ភាវយេ អបរិមាណំ [4]បុគ្គលគួរចម្រើននូវមេត្តាចិត្តមិនមានប្រមាណចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង។

៨. មេត្តញ្ច សព្វលោកស្មិំ, មានសម្ភាវយេ អបរិមាណំ;

ឧទ្ធំ អធោ ច តិរិយញ្ច, អសម្ពាធំ អវេរំ អសបត្តំ [5]បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង

៩. តិដ្ឋញ្ចរំ និសិន្នោ វា, សយានោ វា យាវតស្សវិគតមិទ្ធោ (បុគ្គលអ្នកចម្រើននូវមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាស់ហើយ គឺថាជាអ្នកមិនដេកលក់អស់កាលត្រឹមណា

ឯតំ សតឹ អធិដ្ឋេយ្យ [6]គួរតម្កល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ)

ព្រហ្មមេតំ វិហារំ ឥធមាហុ បណ្ឌិតទាំងឡាយពោលនូវកិរិយានុ៎ះ ថាជាព្រហ្មវិហារក្នុងសាសនានេះ

១០. ទិដ្ឋញ្ច អនុបគម្ម, សីលវា ទស្សនេន សម្បន្នោ;

កាមេសុ វិនេយ្យ គេធំ, នហិ ជាតុគព្ភសេយ្យំ បុន រេតិ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាស គឺថាមិនកើតក្នុងគភ៌ទៀតឡើយ ។

*1-14 សម្តែងអំពីគុណរបស់ព្រះសង្ឃ, ១-១៤ សម្តែងនូវសត្វដែលយើងត្រូវផ្សាយមេត្តាទៅដល់, 1-6 សំណូមពរ

ដកស្រង់ពី បិដកលេខ៥២ ទំព័រ១៨, លេខ៥៤ ទំព័រ៥០), ធម្មបទអដ្ឋកថា ចិត្តវគ្គ រឿងទី ៦ អារទ្ធវិបស្សកភិក្ខុ
ដោយព្រះមហាញាណាវុធៈ ទុយ លីហួរ (15-04-2020)